# ពន្លឺសន្តិភាព

ក្រោយការប្រយុទ្ធនៅ ភូនក្អែក ទិសក្រោយពីយើងត្រឡប់មកពីជួយបង ប្អូនយើងនៅខេត្តពលលាវចំនួនប្រហែលមួយខែមក ទ័ពសម្ព័ន្ធមិត្ត មិនទាន់ហ៊ានចូលមកធ្វើការរៀបរយវិញទេ ប៉ុន្តែជាមួយគ្នានេះ ការស្ទប់ស្ទាត់ក៏កើតមានឡើងសឹងគ្រប់ទិសទី ក្នុងតំបន់មួយ ដែលមានផ្ទៃដីទំហំប្រហែល២០០ គ.ម.២. សាកសព ដែលធ្លាប់ឃើញអណ្តែតតាមព្រែកនានា រាប់រយរាប់ពាន់ ខ្លះរលេះ រលួយអស់ទៅហើយ ខ្លះក៏អណ្តែតកាត់ទីប្រជុំជន បាយនៅ ចេញទៅសមុទ្រអស់ទៅដែរ។

វាក់ងយប់ថ្ងៃទី ៦ កុម្ភៈ ១៩៤៦ គេឃើញលោកតាចៅអធិការ ជាច់ ពេជ លោកតាអាចារ្យ ជាច់ ហ៊ឹម លោកតាសារ ជាអ្នកបំរើព្រះសង្ឃក្នុងវត្តពោធិព្រឹក្ស មេឃុំឈ្មោះ ហួរ ហៅថៅកែ ហួរ អតីតមន្ត្រីឃុំឈ្មោះ វិញ យ៉ុរ៉ង ហ ហៅ តា ហ អុងកាឡា ឌិង គ្រឹង យ៉ាង យ៉ំ ម្ចាស់ហាងលក់មាស «មានគ្រួសារជាខ្មែរ» បានហ្វាងសា

លាចិនដែលយើងក្មេងឈ្មោះ ហ៊ា-ម៉េង ហ៊ា ប៊ុ ហ៊ា គួយ ជាអ្នកមានធនធានស្ដុកស្ដម្ភ បាននិមន្ត និងអញ្ជើញមកជួបយើងក្នុងសេនាធិការដ្ឋាន ក្នុងឋានៈជាអ្នកនាំពាក្យរបស់ពលរដ្ឋយួន និងចិន នៅផ្សារព្រែកគយ ដោយស្នើសុំយើងជួយគេទៅ ៖

—សូមឱ្យលើកសេនាធិការដ្ឋានទៅឯទីប្រជុំជន ដោយគេជូនផ្ទះមួយល្វែង ។

—សូមជួយណែនាំខ្មែរ និងយួន ឱ្យនិយាយស្ដាប់គ្នាបាន លែងប្រកាប់ប្រចាក់គ្នាតទៅទៀត ។

ចំពោះការស្នើរបស់អ្នកនាំពាក្យនេះ យើងបានជំរាបបញ្ជាក់ថា: ដែលយើងទ្រាំទ្រលំបាកកាថាលស្រែ ខោលស្រវាំងពេញវាលផ្លូវនេះ ក៏ដើម្បីសេចក្ដីសុខ និងយុត្តិធម៌ ប្រសិនគេមានបំណងជួយយើងដែរ យើងគ្មានការអ្វីនិងបញ្ជាក់ទៀតទេ ។

មួយថ្ងៃក្រោយមកទៀត ក្រោយពីបានចាត់ការឱ្យប្រុងប្រយ័ត្នគ្រប់ច្រកល្ហកទ្វារឡើងទៀត យើងក៏បានទៅថ្វាយបង្គំលោកតា ពេជ ដើម្បីស្នើយោបល់ក្នុងរឿងនេះ ពីព្រោះយើងពិបាកនឹងទុកចិត្តគេដែរ តាមឧបត្តិហេតុ ដែលយើងបានឃើញជាហូរហែរហូតមកថ្ងៃនេះ ។ ចំពោះយើងវិញ យើងឥតមានសង្ស័យបន្តិចបន្តួចសោះទេថា: ពាក

ប្រយុទ្ធនៅ ក្នុងព្រែក ដែលទើបកន្លងទៅនេះ បានធ្វើឱ្យយើងមានការត្រិះរិះមិនតិចឡើយ ជាពិសេស គេទើបដឹងហើយយើញថា យើងប្រាកដជាមិនព្រមស្លាប់មែន ៗ

ដោយត្រូវគោរពពាក្យបុរាណដែលថា បើដេញទាន់ កុំដាច់កែងនោះ យើងក៏បានធ្វើបទបញ្ជាឱ្យយួនចាត់គ្នាគេទៅហៅមនុស្ស « រាប់ទាំងពួកកងទ្នក់ ឬ យួកិច » ផង រាប់ច្រើនម៉ឺននាក់ ទៅនៅតាមកោះនានា នៅតាមសមុទ្រ ជាពិសេសនៅ កុងស៊ីម ដែលចូលមកធ្វើបាបយើងច្រើនលើក ច្រើនគ្រានោះ មកសុំចុះចូលនិងយើងសិន ៗ

គ្រាន់តែបានដំណឹងនេះភ្លាម ពីរថ្ងៃក្រោយមកមនុស្សម្នាទាំងពាន់ ៗ បានចូលសុំសំបុត្រចុះចូល ៗ ពេលនោះ យើងដែលគ្មានប្រាក់បំណាច់អ្វីមួយសេនគាំងពីដើមទីមក ក៏សុំឱ្យម្នាក់ ៗ ដែលសុំចុះចូល បង់មួយពីយ៉ាស ពីព្រោះយើងត្រូវប្រើស្មៀនជិត២០នាក់ ទើបសរសេរទាន់ ៗ

ដោយឃើញថា ក្នុងកំឡុងតែកន្លះខែសោះ មនុស្សម្នាបានចូលមកប្រកបមុខរបរផ្លូវធម្មតាសីងគ្រប់កន្លែង ដូចនេះ យើងក៏ចាប់មានការទុកចិត្តលើសុទ្ធចិត្តរបស់យួនបង្កិចម្ដង ៗ ទៅដែរ ៗ

* * *

# ពិធីបុណ្យ
# ប្រោសព្រលឹងសាបក្តីតាព

ដើម្បីរំលឹកដល់វិញ្ញាណក្ខ័ន្ធនៃយុទ្ធជនយើង ដែលបានបូជាជីវិតដើម្បីសេរីភាព និងយុត្តិធម៌ និងបងប្អូនយើងដទៃទៀតដែលបាត់បង់ជីវិតក្នុងរាកអន្តរកាលនេះ យើងក៏បានធ្វើបុណ្យបីថ្ងៃ បីយប់ ក្នុងបរិវេណវត្តពោធិព្រឹក្ស ហៅវត្តចាស់ ។ នៅឱកាសនោះមានប្រតិភូ ឃួន-ចិន ស្មៀក គាត់ជាពុទ្ធមាមិកជន តាមរបៀបជាអ្នកកាន់ព្រះពុទ្ធសាសនា ទាន់មហាយ៉ានប្រហែលជា ៣០ក្រុមនាក់ ដឹកនាំដោយ មេចិន និងមេឃួននៅទីនោះ ដូចជាលោក ធៀង យ៉ាង ចាយ ហៅចឹកាយ ចាយ និងអស់លោកអតីតអ្នកមុខ អ្នកការ ចិន- ឃួន ជាច្រើន បានមកចូលរួមក្នុងពិធីបុណ្យយើងនេះផង ។

នៅថ្ងៃទី ៣ មុនពេលឆ្លងបុណ្យ លោកតា ចាប់ ហ៊ឹម ដែលទើបវិលមកកាន់នាទីចាស់របស់គាត់ក្នុងវត្តវិញ ក្រោយពីបានចូលរួមក្នុងការប្រយុទ្ធមួយដ៏ឃោរឃៅនៅ ភូនព្រែក នៅពេលថ្មី ៗ នេះមក បានឡើងធ្វើសុន្ទរកថាមួយទៅកាន់បង ប្អូនយុវជនបញ្ជាក់ពីឆន្ទៈប្ដូរផ្តាច់របស់យើង ចំពោះអំពើអយុត្តិធម៌ និងពីគោលបំណងរបស់យើងទៅអនាគត ។ ដើម្បីតបសន្តិជាលោកតា ចាប់ ហ៊ឹម អតីតចៅសង្កាត់យួន ហៅ ធា ហស់ បានធ្វើការផ្ដែផ្ដាំដល់គណរដ្ឋយួន ឲ្យរិតចំស្រោចស្រង់មិត្តភាពជាមួយ បង ប្អូនយើងវិញ ពីព្រោះយួន និង ខ្មែរ ត្រូវរួមរស់ជាមួយគ្នាតទៅទៀតនៅលើដីនេះ ទោះយើងទាំងអស់គ្នា ចង់ក្តី មិនចង់ក្តី ។

# សកម្មភាព និង រឿង
# អភិវឌ្ឍស្រុកយើង

## ១-សកម្មភាពចៅហ្វាយស្រុកថ្មី

រាំងខែមីនា ១៩៨៦ លោកអភិបាលខេត្តយួនចូលមកដល់ព្រែកគយជាមួយទស្សនមិត្តជាលើកដំបូង តាំងពីជំបុំឲ្យបាញ់សង្គ្រាមទៅ គេបានលើក«បន្ទប់»ថ្មីដោយ ដាក់ឲ្យធ្វើជាអភិបាលស្រុកអណ្តូងទឹក ដែលមានការិយាល័យថ្មីនៅផ្សារព្រែកគយតែម្តង ៗ នៅក្នុងសន្តិភាពរបស់គេ ដែលយើងអាចសន្និដ្ឋានបានថា ពិតមែនតែគេមិនបានយល់ស្របទិសសកម្មភាពរបស់យើងកំពុងទានខែមុននេះក៏ដោយ ក៏គេមិនទុកថាយើងធ្វើនោះខុសទាំងអស់ដែរ ដោយនៅទីអា-សានៃសន្តិភាពរបស់គេៗ បានបញ្ជាក់យ៉ាងច្បាស់ថា . . . ពិតជាដើម្បីជាតិ ដើម្បីប្រទេស ៗ

២— នៅក្នុងមុខដំណែងថ្មីនេះ ចៅហ្វាយស្រុកយើង បានតាំងមន្ត្រីសង្កាត់គ្រប់សង្កាត់ក្នុងស្រុក ដោយយើងបានចាត់តាំងភ្នាក់ងារសង្កាត់គ្រប់សង្កាត់ក្នុងស្រុក ដោយរើសបានតែមនុស្សដែលមានកំណើតជាខ្មែរ ៗ ពលរដ្ឋយួនត្រូវទទួលតែត្រឹមតំណែង មេភូមិ ឬ ស្មៀន ហើយសម្រាប់តែសង្កាត់ណាដែលមានសុទ្ធតែពលរដ្ឋយួនរស់នៅ ៗ

ដើម្បីបង្ហាញនូវសុទ្ធចិត្តរបស់យើង យើងបានខិតខំប្រឹងប្រមូលខ្មែរ និង យួនឲ្យរួមរស់ជាមួយគ្នាដូចដើម ដើម្បីបំពេញកិច្ចការរួម ដោយឥតមានប្រកាន់ជាតិសាសន៍សោះឡើយ ៗ ក្រោយមកទៀត រដ្ឋការយួនក៏បានប្រគល់អាវុធ និង គ្រាប់រំសេវជាច្រើនមកដល់យើង ដែលយើង និង យួនបានប្រើអាវុធនោះជាមួយគ្នា ដើម្បីបង្ក្រាបអំពើចោរកម្ម ដែលមានកើតឡើង ដោយសារអ្នកទោសរត់ពីកោះត្រឡាច បង្ករបង្កើតឡើង ៗ

៣ មានការរំដោះលោកសង្ឃ និងដូនជីកាតូលិកនៅភូមិដងក្តោង ឲ្យចាកផុតពីភ័យអន្តរាយ ៗ បានកំចាត់ក្រុមចោរកំណាចមួយក្រុម នៅពេលដែលវាកំពុងចាប់កូនក្រមុំអ្នកស្រុក និងជញ្ជូនស្រាំងដាក់ក្នុងទូកប្រឯងទូងទៅពួនតាមកោះក្នុងសមុទ្រ ៗ ក្រោយពីចោរកាប់ចំដោយ ដាក់ បាក់កាំភ្លើងនៅពេលប្រតាយប្រតប់គ្នាមក អ្នកស្រុកមួយក្រុមបានចូលជួយ

ប្រយុទ្ធ ហើយចាប់បានមេកំយកទៅសម្លាប់ភ្លាមទៅ ។ អ្នកដែលសម្លាប់អាចោរ មានផុកខាងកញ្ញាងគ្រោះ អ្នកម្ចាស់របស់ និងក្រុមញាតិជាមួយអ្នកភូមិជងរបងជាមួយ នៅក្នុងភូមិមួយនៅជិតភូមិមាន់គោង ។

៦— រួចហើយយើងក៏ចាត់ចែងចែកអំបិល រាប់ច្រើន ពាន់តោនសល់ពីជប៉ុន ហើយដែលជាប្រភពមួយដែរក្នុងជម្លោះរវាងយើង និង យួន ម្តងណោះដោយគ្មានប្រកាន់ពូជសាសន៍ដូចមុនៗទៀតឡើយ ។

៧- តាមការអំពាវនាវរបស់យើង ពលរដ្ឋយួន-ចិន នៅផ្សារព្រែកតយ-ក្លូនក្អែក-បឹងព្រលិត បានរួបរួមគ្នា ជាមួយយើងដើម្បីជួសជុលវត្តក្លូនក្អែកឡើងវិញ មិនតែប៉ុណ្ណោះ យើងបានកសាងស្ពានឈើបានពីរនិងរៀបចំផ្លូវក្បែរវត្តពោធិព្រឹក្ស ដោយយួន-ចិន គេសុខចិត្តលាយខ្ទាចជំនួន-ជំគាគេចេញ ដើម្បីបង្ហាញការស្មោះត្រង់ របស់គេមកលើប្រយោជន៍រួមជាតិ បង្ហាញថាយើងនិងយួនល្មមជៀតគ្នាវិញបានផង ។